## តើខ្ញុំអាចទទួលជំនួយនៅកន្លែងណាទៀត?

ការិយាល័យសេវាកម្មសហគមន៍ខ្លះមានអ្នកការពារអំពើហឹង្សាក្នុងគ្រួសារដែលធ្វើការនៅទីនោះដើម្បីជួយអ្នក ។ អ្នកទាំងនេះមានជំនាញខាងអំពើហឹង្សាក្នុងគ្រួសារ និងអាចជួយអ្នកគិតអំពីជម្រើសរបស់អ្នក គម្រោងសម្រាប់សុវត្ថិភាពរបស់អ្នក និងតភ្ជាប់អ្នកជាមួយធនធានផ្សេងទៀតក្នុងសហគមន៍របស់អ្នក ។

ដើម្បីស្វែងរកកម្មវិធីការការពារអំពើហឹង្សាក្នុងគ្រួសារក្នុងតំបន់របស់អ្នកអ្នកអាចទូរស័ព្ទទៅខ្សែអំពើហឹង្សាក្នុងគ្រួសារដោយឥតគិតថ្លៃតាមលេខ 1-800-799-7233 ។



WASHINGTON WorkFirst

Washington State Department of Social & Health Services

Transforming lives

DSHS 22-265 CA (Rev. 7/18)

# បើក ទ្វារ



# ដើម្បីថ្ងៃស្អែក ដែល ស្រស់ថ្លា

ជំនួយសម្រាប់ជនរងគ្រោះនៃអំពើហឹង្សាក្នុងគ្រួសារ

# តើមាននរណាម្នាក់ធ្វើបាបអ្នកឬតើអ្នកបានទទួលរងការឈឺចាប់មែនទេ?

## តើអ្នកភ័យខ្លាចដៃគូចាស់ ឬ សមាជិកគ្រួសារនៃដៃគូ **របស់អ្នក** មែនទេ?



មានមនុស្សជាច្រើនដែលនឹងជួយអ្នករៀបគម្រោងសុវត្ថិភាពរបស់អ្នក ។ ពួកគេនឹងជួយអ្នកស្វែងរកកន្លែងមានសុវត្ថិភាពដើម្បីស្នាក់នៅ ទទួលការប្រឹក្សា និងជំនួយផ្នែកច្បាប់ ។ ពួកគេក៏នឹងជួយអ្នកឈានជំហានផ្សេងទៀតដើម្បីសម្រេចភាពឯករាជ្យ និងជួយអ្នកបានជោគជ័យ ។

ពួកយើងយល់ថាមនុស្សជាច្រើនរស់នៅជាមួយអំពើហឹង្សាក្នុងគ្រួសារហើយពួកយើងយកចិត្តទុកដាក់ពីការជួយរក្សាសុវត្ថិភាពគ្រួសារ ។ ពេលដែលអ្នកដាក់ពាក្យសម្រាប់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ (TANF) ពួកយើងនឹងសួរអ្នកពីសំណួរខ្លះដើម្បីដឹងថាអំពើហឹង្សាក្នុងគ្រួសារគឺជាបញ្ហាសម្រាប់អ្នក ឬគ្រួសាររបស់អ្នក ។

> សូមចំណាំ ៖ អ្នកអាចសម្រេចថាតើអ្នកចង់ប្រាប់ពួកយើងអំពីបទពិសោធន៍ជាមួយការរំលោភបំពាន ឬអំពើហឹង្សាក្នុងគ្រួសារ ឬក៏អត់ ។ អ្នកអាចនិយាយជាមួយពួកយើងអំពីអំពើហឹង្សាក្នុងគ្រួសារគ្រប់ពេល ។

### តើអ្វីជាអំពើហឹង្សាក្នុងគ្រួសារ?

អំពើហឹង្សាក្នុងគ្រួសារមានន័យថាដៃគូ ឬសមាជិកគ្រួសារប្រើរបៀបនៃការគ្រប់គ្រង និងអាកប្បកិរិយារំលោភបំពានប្រឆាំងនឹងដៃគូ ឬសមាជិកគ្រួសារផ្សេងទៀត ។ អាកប្បកិរិយារំលោភបំពានទាំងនេះអាចតាមផ្លូវចិត្ត ផ្លូវភេទ រាងកាយ ឬសេដ្ឋកិច្ច ។ ឧទាហរណ៍ខ្លះៗមាន ៖

- ការបំបាក់មុខ ការហៅឈ្មោះអាក្រក់ ឬការធ្វើឲ្យអ្នកខ្មាស់គេដដែលៗ ។
- ការមិនឲ្យអ្នកទាក់ទងជាមួយគ្រួសារ ឬមិត្តភក្តិរបស់អ្នក ។
- ការគ្រប់គ្រងការអាចប្រើប្រាស់ប្រាក់របស់អ្នក ។
- ការគំរាមធ្វើឲ្យអ្នក កូនរបស់អ្នក សត្វចិញ្ចឹមរបស់អ្នក ឬរបស់របររបស់អ្នកខូចខាត ។
- រំលោភបំពានរាងកាយអ្នក ។
- ការដាក់សម្ពាធលើអ្នកអំពីបញ្ហាផ្លូវភេទ ។
- ការតាមដានអ្នក ។
- ការបញ្ឈប់អ្នកពីការទទួលបាន ឬរក្សាការងារ ។

### តើពួកយើងជួយយ៉ាងដូចម្តេច?

បើអំពើហឹង្សាក្នុងគ្រួសារគឺជាបញ្ហាសម្រាប់អ្នក ហើយអ្នកព្រួយបារម្ភអំពីការបំពេញតម្រូវការ WorkFirst របស់អ្នក និយាយជាមួយបុគ្គលិកសំណុំរឿង ឬបុគ្គលិកសង្គមរបស់អ្នក ។ ពួកយើងអាច ៖

- លើកលែងអ្នកពីតម្រូវការស្វែងរកការងារ ឬការមានការងារ ។
- លើកលែងអ្នកពីការប្រមូលជំនួយកុមារ (ដែលហៅថា "បុព្វហេតុល្អ") ។

បើអ្នកជ្រើសរើសប្រាប់ពួកយើងអំពីអំពើហឹង្សាក្នុងគ្រួសារ ពួកយើងអាចបញ្ចូលសកម្មភាពក្នុងគម្រោងការទទួលខុសត្រូវផ្ទាល់ខ្លួន (IRP) របស់អ្នកដើម្បីរក្សាសុវត្ថិភាពដល់អ្នក និងគ្រួសាររបស់អ្នកដូចជា ៖

- ការចូលរួមប្រឹក្សា និងជំនួយក្រុម ។
- ស្វែងរកជំនួយផ្នែកច្បាប់ និងការការពារ ។
- ការរៀបគម្រោងសុវត្ថិភាព ។

ពួកយើងដឹងថាអំពីអំពើហឹង្សាក្នុងគ្រួសារអាចជ្រៀតជ្រែកសមត្ថភាពរបស់អ្នកដើម្បីមានស្ថេរភាពផ្នែកហិរញ្ញវត្ថុ ហើយពួកយើងចង់ជួយអ្នកតាមវិធីដែលពួកយើងអាចជួយបាន ។

### អ្នក និងគ្រួសាររបស់អ្នកមានសារៈសំខាន់សម្រាប់ពួកយើង

ពួកយើងមានគោលនយោបាយជាស្រេចដើម្បីការពារព័ត៌មានដែលអ្នកប្រាប់ពួកយើង ។ បើអ្នកព្រួយបារម្ភអំពីអ្វីនឹងកើតឡើងដល់ព័ត៌មានដែលអ្នកឲ្យពួកយើង សូមនិយាយជាមួយបុគ្គលិកសំណុំរឿង WorkFirst របស់អ្នក បុគ្គលិកសង្គម ឬអ្នកការពារអំពើហឹង្សាក្នុងគ្រួសារមុននឹងចែករំលែកព័ត៌មានរសើប ។

បើអ្នកប្រាប់ពួកយើងថាកូនរបស់អ្នកណាមួយកំពុងត្រូវបានរំលោភបំពាន ពួកយើងត្រូវបានតម្រូវឲ្យរាយការណ៍ព័ត៌មានដល់ផ្នែកសេវាកម្មកុមារ និងគ្រួសារ ឬទីភ្នាក់ងារអនុវត្តច្បាប់ ។ (RCW 26.44.030(4))